អត្ថបទត្រួតពិនិត្យចុងក្រោយ

អង្គការសហប្រជាជាតិ **E**

---

ក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គមកិច្ច

ការចែកចាយ :
ទូទៅ
E/C.12/KHM/CO/1
ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩
អត្ថបទដើម : ភាសាអង់គ្លេស

---

**គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌**
សម័យប្រជុំលើកទីសែសិបពីរ
៤ - ២២ ខែឧសភា ឆ្នាំ២០០៩

# ការពិនិត្យពិចារណាលើរបាយការណ៍ដែលបានស្នើដោយរដ្ឋភាគី ក្រោមមាត្រា១៦ និងមាត្រា១៧ នៃកតិកាសញ្ញានេះ

## សេចក្តីសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## កម្ពុជា

១. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានពិនិត្យពិចារណាលើរបាយការណ៍បញ្ចូលគ្នានៃរបាយការណ៍លើកដំបូង និងរបាយការណ៍តាមកាលកំណត់លើកទីពីរ រហូតដល់លើកទីបួនរបស់កម្ពុជា ស្តីពីការអនុវត្តន៍កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (E/C.12/KHM/1) នាសម័យប្រជុំរបស់ខ្លួនលើកទី១១ ទី១២ និងទី១៣ (E/C.12/2009/SR.11,12 and 13) ដែលបានធ្វើឡើងនៅថ្ងៃទី១១ និងទី១២ ខែឧសភា ឆ្នាំ២០០៩ ហើយបានអនុម័តសេចក្តីសន្និដ្ឋានចុងក្រោយនៃរបាយការណ៍ទាំងនោះនាសម័យប្រជុំលើកទី២៦ របស់ខ្លួន ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩ ដូចខាងក្រោមនេះ ៖

## ក. សេចក្តីផ្តើម

២. គណៈកម្មាធិការស្វាគមន៍ការដាក់ស្នើរបាយការណ៍បញ្ចូលគ្នានៃរបាយការណ៍លើកដំបូង និងរបាយ-ការណ៍តាមកាលកំណត់លើកទីពីរ រហូតដល់លើកទីបួន របស់កម្ពុជា ប៉ុន្តែមានការសោកស្តាយចំពោះការយឺតយ៉ាងក្នុងការដាក់ស្នើរបាយការណ៍នេះរយៈពេល១៤ ឆ្នាំមកនេះ។ គណៈកម្មាធិការបានស្វាគមន៍ផងដែរ ចំពោះការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងបញ្ជីសំណួរ/បញ្ហារបស់ខ្លួន (E/C.12/KHM/Q/1) ប៉ុន្តែគណៈកម្មាធិការមានការសោកស្តាយដោយសារថា សំណួរមួយចំនួននៅមិនទាន់បានឆ្លើយ ។

៣. គណៈកម្មាធិការវាយតំលៃខ្ពស់ចំពោះឱកាសជួបពិភាក្សាជាមួយតំណាងនានានៃរដ្ឋភាគី និងបានទទួលចំលើយទៅនឹងសំណួរទាំងឡាយដែលគណៈកម្មាធិការបានលើកឡើង ។ គណៈកម្មាធិការមានការសោកស្តាយចំពោះអវត្តមានអ្នកជំនាញការពីរដ្ឋភាគី ហើយថាព័ត៌មានដែលបានផ្តល់ក្នុងករណីខ្លះមិនបាននិយាយលំអិតគ្រប់គ្រាន់ ដើម្បីឲ្យគណៈកម្មាធិការអាចធ្វើការវាយតំលៃបានពេញលេញជាងនេះ អំពីកំរិតនៃការទទួលបានសិទ្ធិដែលមានចែងក្នុងកតិកាសញ្ញានេះ នៅក្នុងរដ្ឋភាគី ។

## ខ. ទិដ្ឋភាពវិជ្ជមាន

៤. គណៈកម្មាធិការកត់សំគាល់ដោយក្តីពេញចិត្ត នូវការប្រកាសអំពីសិទ្ធិមនុស្សនៅក្នុងរដ្ឋធម្មនុញ្ញរបស់រដ្ឋភាគី ត្រង់ជំពូកទីIII ដែលគ្រប់ដណ្តប់លើសិទ្ធិជាច្រើនខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។ គណៈកម្មាធិការបានស្វាគមន៍ផងដែរ ចំពោះសេចក្តីសំរេច ចុះខែកក្កដា ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញថា សន្ធិសញ្ញាអន្តរជាតិគឺជាផ្នែកមួយនៃច្បាប់ជាតិ ហើយថា តុលាការត្រូវតែយកបញ្ញត្តិនានាដែលមានចែងក្នុងសន្ធិញ្ញាទាំងនោះមកពិចារណានៅពេលធ្វើការបកស្រាយច្បាប់ និងសំរេចអំពីបណ្តឹងផ្សេងៗ ។

៥. គណៈកម្មាធិការស្វាគមន៍ចំពោះយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងកម្មវិធីនានារបស់ខ្លួន ដើម្បីពង្រឹងអភិបាលកិច្ចល្អ និងការគោរពសិទ្ធិមនុស្ស ក្នុងចំណោមវិស័យជាច្រើនទៀត ។

៦. គណៈកម្មាធិការកត់សំគាល់ដោយក្តីពេញចិត្តថា អនុលោមតាមរបាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអាណត្តិក្នុងឆ្នាំ២០០៨ ស្តីពីផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ឆ្នាំ២០០៦ - ២០១០ ដែលក្នុងនោះមានការឲ្យផ្អាកកាប់ឈើជាបណ្តោះអាសន្នចំពោះសម្បទានព្រៃឈើទាំងឡាយដែលមានស្រាប់ បទល្មើសព្រៃឈើចំនួន ២១៥៨ ករណី ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធតាមដាន ជនល្មើសចំនួន ៦០៦

នាក់ ត្រូវបានចាប់ខ្លួននិងបញ្ជូនទៅតុលាការ ហើយថាដីព្រៃចំនួន ២១៥៥២១ ហិកតា ដែលគេទន្ទ្រានយក ត្រូវបានដកហូតមកវិញ ។

៧. គណៈកម្មាធិការស្វាគមន៍ចំពោះការដែលរដ្ឋភាគីប្រកាសបើកគំរោងផ្តល់ឥណទានធ្វើឲ្យសំរាប់ព្រៃសហគមន៍ ក្រោមយន្តការអភិវឌ្ឍន៍ភាពស្អាត និងការកាត់បន្ថយការបំពុលផ្សេង និងការកាប់បំផ្លាញព្រៃឈើ និងការធ្វើឲ្យអន្តរាយដល់ព្រៃឈើ នៃអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីភាពបម្រែបម្រួលនៃអាកាសធាតុ ។

៨. គណៈកម្មាធិការកត់សំគាល់ដោយក្តីពេញចិត្ត អំពីវិធានការច្បាប់ និងវិធានការឯទៀត ដែលរដ្ឋភាគីបានអនុម័ត ដើម្បីលើកកំពស់ការទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ជាពិសេស ៖

(ក) ការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាសំរាប់គោលបំណងរៀបចំរបាយការណ៍ស្តីពីសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលរដ្ឋភាគីបានផ្តល់សច្ចាប័ន ។

(ខ) ការបង្កើតអាជ្ញាធរមីនកម្ពុជា មជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា(CMAC) និងការបោសសំអាតមីនលើផ្ទៃដី ៤៧៦៥០ ហិកតា ដែលក្នុងនោះ ២៨៥៩០ ហិកតា គឺជាដីកសិកម្ម ហើយ ១៦៩៨ ហិកតាទៀត ជាដីភូមិ និង ដីសហគមន៍ ។

(គ) ការអនុម័តក្នុងឆ្នាំ២០០៧ នូវច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ដែលធ្វើនិយតកម្មការផ្គត់ផ្គង់ទឹក ប្រព័ន្ធស្រោចស្រប់ និងប្រព័ន្ធបង្ហូរទឹក និងការគ្រប់គ្រងការស្តុកទឹកលើដី និងការប្រើប្រាស់ទឹកក្រោមដី ។

(ឃ) អនុក្រឹត្យលេខ ១០៣ ចុះខែធ្នូ ឆ្នាំ២០០០ ស្តីពីការចុះបញ្ជីកំណើត ។

(ង) ផែនការយុទ្ធសាស្ត្រ ឆ្នាំ២០០៦ - ២០១០ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលផ្តល់សេវាកម្មពិសេសសំរាប់បុគ្គលដែលត្រូវការជាពិសេស ដូចជា យុវជន ជនពិការ ជាពិសេសនៅក្នុងក្រុមអនីតិជន ។

(ច) ការបង្កើតផែនការជាតិលើកទីពីរ ប្រឆាំងការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទ ២០០៦ - ២០១០ ។

(ឆ) ការបង្កើតផែនការសកម្មភាពជាតិ សំរាប់ឆ្នាំ២០០៨ - ២០១២ ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។

៩. គណៈកម្មាធិការកត់សំគាល់ដោយក្តីពេញចិត្ត អំពីការអនុម័តវិធានការផ្សេងៗក្នុងគោលបំណងលើកកំពស់ឲ្យស្ត្រីទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដោយរួមទាំង ៖

(ក) គណៈកម្មាធិការស្វាគមន៍ការអនុម័តគោលការណ៍ ដែលចេញដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ឆ្នាំ២០០៨ ណែនាំដល់គ្រប់ស្ថាប័នរដ្ឋាភិបាលទាំងអស់ឲ្យអនុវត្តវិធានការពិសេសបណ្តោះអាសន្ន ដោយតម្រូវឲ្យទទួលយកស្ត្រីរវាង២០ ទៅ ៥០% នៅពេលជ្រើសរើសបុគ្គលិកថ្មីឲ្យចូលបំរើការងារ ។

(ខ) ការបង្កើតគោលនយោបាយជាតិ និងគោលនយោបាយសិចទ័រស្តីពីបញ្ហាយ៉េនឌ័រ ក៏ដូចជាផែនការយុទ្ធសាស្ត្រប្រចាំឆ្នាំរបស់ក្រសួងកិច្ចការនារី *នារីរតនៈ II (ស្ត្រីគឺជាត្បូងមានតំលៃ)*។

(គ) ការបង្កើតក្រុមប្រឹក្សាជាតិ ដើម្បីស្ត្រីក្នុងឆ្នាំ២០០១ ។

(ឃ) ការអនុម័តច្បាប់ស្តីពីការបង្ការអំពើហឹង្សាក្នុងគ្រួសារ ការការពារជនរងគ្រោះក្នុងឆ្នាំ២០០៥ ។

(ង) ការចូលជាធរមានក្នុងខែសីហា ឆ្នាំ២០០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ។

(ច) ផែនការយុទ្ធសាស្ត្រឆ្នាំ២០០៨ - ២០១២ ស្តីពីស្ត្រី និងជំងឺអេដស៍ នៃក្រសួងសុខាភិបាល ក្នុងគោលបំណងអប់រំ និងផ្សព្វផ្សាយព័ត៌មានអំពីបញ្ហាសុខភាពដែលប៉ះពាល់ដល់ស្ត្រី និងជាពិសេសសុខភាពខាងការបន្តពូជ ។

១០. គណៈកម្មាធិការស្វាគមន៍ការផ្តល់សច្ចាប័ន ដោយរដ្ឋភាគី នូវ ៖

(ក) ពិធិសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ក្នុងឆ្នាំ២០០៧ ។

(ខ) ពិធិសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ និងពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ក្នុងឆ្នាំ២០០០ ។

## គ. កត្តា និង ការលំបាកផ្សេងៗ ដែលជាឧបសគ្គដល់ការអនុវត្តន៍កតិកាសញ្ញា

១១. គណៈកម្មាធិការកត់សំគាល់អំពីការងើបផុតរបស់រដ្ឋភាគីពីភាពឯកកោ និងការបំផ្លិចបំផ្លាញដែលបានកើតឡើងដោយសារសង្គ្រាមរយៈពេលជាងពីរទសវត្សរ៍ បាននាំឲ្យដំណើរការយឺតយ៉ាវ និងមានការលំបាកជាច្រើន ។ គណៈកម្មាធិការកត់សំគាល់ជាពិសេសថា អំពើប្រល័យពូជសាសន៍ដ៏មហាសោកនាដកម្មទៅលើប្រជាជនជាច្រើននាក់ រួមទាំងអ្នកវិជ្ជាជីវៈក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានធ្វើឲ្យរដ្ឋភាគីបាត់បង់អស់អ្នកជំនាញការចាំបាច់សំរាប់ការស្តារប្រទេសជាតិឡើងវិញ ក្នុងជំហ៊ានមួយដែលគាប់ចិត្តជាងនេះ ។

## ឃ. កម្មវត្ថុចម្បងៗនៃកង្វល់ និងអនុសាសន៍

១២. គណៈកម្មាធិការមានការសោកស្តាយថា បើទោះជារដ្ឋធម្មនុញ្ញធានាការពារហើយក្តី ក៏នៅក្នុងការអនុវត្តន៍ជាក់ស្តែង បទបញ្ញត្តិនៃកតិកាសញ្ញានេះនៅមិនទាន់ត្រូវបានគេលើកមកសំអាងនៅចំពោះមុខ ឬដោយផ្ទាល់នៅតុលាការជាតិ សាលាក្តី ឬអាជ្ញាធររដ្ឋបាលនៃរដ្ឋភាគីឡើយ ។ ដូច្នេះ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់អំពី ការខ្វះការដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះអំពើរំលោភសិទ្ធិមនុស្ស រួមទាំង សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលធ្វើឲ្យរដ្ឋភាគីមិនមានលទ្ធភាពក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលខ្លួនបានផ្តល់សច្ចាប័ន រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

> គណៈកម្មាធិការសូមទាញចំណាប់អារម្មណ៍របស់រដ្ឋភាគីចំពោះសេចក្តីផ្តល់មតិទូទៅរបស់ខ្លួន លេខ៩ (១៩៩៨) ស្តីពីការអនុវត្តន៍ក្នុងស្រុកនៃកតិកាសញ្ញានេះ និងសូមផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីចាត់វាល់វិធានការសមស្រប ដើម្បីធានាការអនុវត្តន៍ដោយផ្ទាល់នូវបទបញ្ញត្តិនៃកតិកាសញ្ញានេះ នៅក្នុងលំដាប់គតិយុត្តក្នុងស្រុករបស់ខ្លួន ដោយរួមទាំងការរៀបចំឲ្យមានកម្មវិធីបណ្តុះបណ្តាលចៅក្រម មេធាវី និងមន្ត្រីសាធារណៈនានា ។ គណៈកម្មាធិការស្នើផងដែរឲ្យរដ្ឋភាគីដាក់បញ្ចូលទៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន នូវព័ត៌មានលំអិតស្តីពីការរីកចំរើនដែលបានធ្វើឡើងពាក់ព័ន្ធនឹងបញ្ហាទាំងនេះ និងអំពីសេចក្តីសំរេចនានារបស់តុលាការជាតិ សាលាក្តី ឬអាជ្ញាធរសាធារណៈ ដែលផ្តល់អានុភាពដល់សិទ្ធិទាំងឡាយដែលមានចែងក្នុងកតិកាសញ្ញានេះ ។

១៣. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់អំពីអវត្តមាននៅក្នុងរដ្ឋភាគី នូវស្ថាប័នសិទ្ធិមនុស្សជាតិមួយឯករាជ្យ ស្របតាមគោលការណ៍ទីក្រុងប៉ារីស ។

គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងមុតមាំថា អនុលោមតាមសំណើរបស់នាយករដ្ឋមន្ត្រី ចុះខែកញ្ញា ឆ្នាំ២០០៦ រដ្ឋភាគីគួរពន្លឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយឯករាជ្យ ស្របតាមគោលការណ៍ទីក្រុងប៉ារីស ។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីធានាថា ស្ថាប័នសិទ្ធិមនុស្សជាតិមួយដែលនឹងបង្កើតឲ្យមាននេះ គួរតែមានអាណត្តិការពារ និងលើកស្ទួយបទបញ្ញត្តិនៃកតិកាសញ្ញានេះ ហើយគួរតែផ្តល់ឲ្យស្ថាប័ននេះនូវធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សំរាប់ប្រតិបត្តិការរបស់ខ្លួនដោយឯករាជ្យ ។ ដូច្នេះ គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យស្វែងរកការជួយឧបត្ថម្ភផ្នែកបច្ចេកទេសពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ។

១៤. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់អំពីរបាយការណ៍ស្តីពីការខ្វះឯករាជ្យភាព និងប្រសិទ្ធភាពនៃប្រព័ន្ធតុលាការកម្ពុជា ដែលរារាំងដល់ការទទួលបានពេញលេញនូវសិទ្ធិមនុស្ស ដោយរួមទាំងសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ ។ គណៈកម្មាធិការមានការភ្ញាក់ផ្អើលនឹងរបាយការណ៍ដែលថា ទោះបីជាមានការខិតខំប្រឹងប្រែងដោយរដ្ឋភាគីក្តី ក៏អំពើពុករលួយនៅតែមានជាទូទៅ ដោយរួមទាំងនៅក្នុងប្រព័ន្ធយុត្តិធម៌ ។

គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យអនុម័តសេចក្តីព្រាងច្បាប់របស់ខ្លួនស្តីពីការប្រឆាំងអំពើពុករលួយ ដោយគ្មានការអូសបន្លាយពេលវេលា និងពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីធ្វើទំនើបកម្ម និងធ្វើឲ្យប្រសើរឡើងថែមទៀតនូវការងាររបស់តុលាការ រួមទាំងតាមរយៈគំរោងថ្មីសំរាប់កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការផ្តន្ទាទោសករណីនៃអំពើពុករលួយ និងពិនិត្យឡើងវិញនូវគោលនយោបាយរបស់ខ្លួន ស្តីពីការកាត់ទោសបទល្មើសពាក់ព័ន្ធនឹងអំពើពុករលួយ ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ផងដែរថា រដ្ឋភាគីគួររៀបចំបង្កើតកម្មវិធីបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់នគរបាល និងមន្ត្រីប្រតិបត្តិច្បាប់ ព្រះរាជអាជ្ញា និងចៅក្រម អំពីការអនុវត្តន៍យ៉ាងម៉ឺងម៉ាត់នូវវិធានការ និងច្បាប់ប្រឆាំងអំពើពុករលួយ និងអនុម័តយន្តការមានប្រសិទ្ធភាព ដើម្បីធានាតម្លាភាពក្នុងដំណើរការរបស់អាជ្ញាធរសាធារណៈ ទាំងក្នុងការអនុវត្តន៍ច្បាប់ទាំងក្នុងការអនុវត្តន៍ជាក់ស្តែង ។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់ក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននូវព័ត៌មានលំអិតទាក់ទងនឹងសមិទ្ធិផលដែលសំរេចបាន និងការលំបាកផ្សេងៗ ដែលរដ្ឋភាគីបានជួបប្រទះ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។

១៥. គណៈកម្មាធិការមានកង្វល់ជាខ្លាំងអំពីរបាយការណ៍អង្កេតស្តីពីព្រៃឈើពិភពលោករបស់អង្គការស្បៀងអាហារ និង កសិកម្ម (FAO) ដែលវាយតំលៃថា រដ្ឋភាគីបានបាត់បង់ ២៩ % នៃព្រៃសំខាន់របស់ខ្លួននៅតំបន់ត្រូពិក ក្នុងអំឡុងពេលជាងប្រាំឆ្នាំកន្លងមកនេះ ករណីមួយក្នុងចំណោមករណីធ្ងន់ធ្ងរបំផុតនោះគឺការកាប់បំផ្លាញព្រៃឈើនៅតែមាននៅតំបន់ព្រៃឡង់ ភាគឧត្តរនៃប្រទេសកម្ពុជា ។ គណៈកម្មាធិការមានកង្វល់ផងដែរ អំពីរបាយការណ៍ដែលថាមានកំណើនយ៉ាងឆាប់រហ័សនូវសម្បទានដីសេដ្ឋកិច្ចនៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ សូម្បីតែនៅក្នុងតំបន់ការពារក៏មានដែរ នេះជាកត្តាធំមួយនៃការធ្វើឲ្យអន្តរាយដល់ធនធានធម្មជាតិ ដែលផ្តល់ផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងជីវចម្រុះ ដែលបណ្តាលឲ្យជនជាតិដើមភាគតិចបាត់បង់ដីធ្លីរបស់ខ្លួនដោយមិនមានការផ្តល់សំណងត្រឹមត្រូវ និងការតាំងលំនៅថ្មី និងការបាត់បង់របរចិញ្ចឹមជីវិតសំរាប់សហគមន៍ជនបទនានា ដែលពឹងអាស្រ័យលើធនធានដីធ្លី និងព្រៃឈើសំរាប់ការរស់នៅរបស់ខ្លួន (មាត្រា ១)

> គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យពិនិត្យឡើងវិញនូវគោលនយោបាយរបស់ខ្លួនពាក់ព័ន្ធនឹងការបង្វែរតំបន់ការពារឲ្យទៅជាសម្បទានសេដ្ឋកិច្ច ដោយមិនបានធ្វើការវាយតំលៃពីផលប៉ះពាល់ខាងសង្គម និងបរិស្ថានជាមុន ជាមួយស្ថាប័នជាដៃគូពាក់ព័ន្ធ និងសហគមន៍នានាដោយគោរពយ៉ាងត្រឹមត្រូវចំពោះសិទ្ធិរបស់ពួកគាត់ ដើម្បីចូលរួមក្នុងការសំរេចផ្សេងៗដែលពួកគាត់ត្រូវតែបានដឹងជាមុន អំពីបញ្ហាទាំងឡាយដែលប៉ះពាល់ដល់ការរស់នៅរបស់ខ្លួន ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងថា ការផ្តល់សម្បទានសេដ្ឋកិច្ច គួរតែគិតគូរអំពីសេចក្តីត្រូវការសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់រូបទទួលបានអត្ថប្រយោជន៍ពីការរីកចំរើននេះ ជាជាងសំរាប់តែផលប្រយោជន៍របស់បុគ្គលឯកជន ។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីបញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននូវព័ត៌មានលំអិតស្តីពីសមិទ្ធិផលដែលសំរេចបានក្នុងការអនុវត្តន៍គោលនយោបាយទាំងនេះ ។

១៦. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ថា ច្បាប់ភូមិបាល ឆ្នាំ២០០១ ដែលចែងអំពីកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច នៅមិនទាន់បានអនុវត្តប្រកបដោយប្រសិទ្ធភាពនៅឡើយ ហើយកន្លងមក មិនមានសហគមន៍ជនជាតិដើមភាគតិចណាមួយបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីនៅឡើយទេ ។ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ដែរថា ផលប៉ះពាល់អវិជ្ជមាននៃការធ្វើអាជីវកម្មលើធនធានធម្មជាតិ ជាពិសេសការរុករករ៉ែ និងការធ្វើអាជីវកម្មប្រេង ដែលបាននិងកំពុងដំណើរការនៅក្នុងដែនដីរបស់ជនជាតិដើមភាគតិច គឺផ្ទុយទៅនឹងសិទ្ធិរបស់ជនជាតិដើមភាគតិច ចំពោះដែនដី ដីធ្លី និងធនធានធម្មជាតិនៃបុព្វបុរសរបស់ពួកគាត់ (មាត្រា ១)

គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យអនុវត្តច្បាប់ភូមិបាល ឆ្នាំ២០០១ ដោយមិនត្រូវអូសបន្លាយពេលវេលាតទៅទៀត និងធានាថាគោលនយោបាយរបស់ខ្លួនស្តីពីការចុះបញ្ជីដីមិនត្រូវឲ្យផ្ទុយនឹងស្មារតីនៃច្បាប់នេះឡើយ ។ គណៈកម្មាធិការបញ្ជាក់អំពីសេចក្តីត្រូវការឲ្យមានការវាយតំលៃអំពីផលប៉ះពាល់ខាងសង្គម និងបរិស្ថាន និងការពិគ្រោះយោបល់ជាមួយសហគមន៍នានាដែលរងផលប៉ះពាល់ ពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ច រួមទាំង ការធ្វើអាជីវកម្មរ៉ែ និងអាជីវកម្មប្រេង ក្នុងគោលដៅធានាថា សកម្មភាពទាំងនេះ មិនត្រូវដកហូតពីជនជាតិដើមភាគតិចនូវការទទួលបានយ៉ាងពេញលេញនូវសិទ្ធិរបស់ពួកគាត់លើដីធ្លី និងធនធានធម្មជាតិនៃបុព្វបុរសរបស់ខ្លួនឡើយ ។ គណៈកម្មាធិការជំរុញលើកទឹកចិត្តឲ្យរដ្ឋភាគីពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៦៩ របស់អង្គការពលកម្មអន្តរជាតិ (ILO 169) ស្តីពីជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ ។

១៧. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ថា ទោះបីជារដ្ឋភាគីបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែមនៃអនុសញ្ញានេះ ក្នុងឆ្នាំ២០០៧ ហើយក្តី ក៏មិនទាន់មានច្បាប់ណាមួយចែងជាក់លាក់ដែលហាមប្រាមការរើសអើងចំពោះជនពិការ ហើយថា មិនមានបញ្ញត្តិ ឬច្បាប់ ឬបទដ្ឋានគតិយុត្តិណាមួយដែលតម្រូវឲ្យក្រសួងមន្ទីរសាធារណៈ និងសេវានានារបស់រដ្ឋាភិបាល ត្រូវតែទទួលយកជនពិការឲ្យចូលបំរើការងារទេ ។ គណៈកម្មាធិការមានកង្វល់អំពីរបាយការណ៍ថា ជនពិការទទួលរងនូវការប្រកាន់បែងចែកដោយមិនសមស្រប ថាពួកគាត់មិនអាចផ្តល់ប្រយោជន៍ដល់សង្គម ដោយសារតែពួកគេពិបាកនឹងរកបានការងារជំនាញ (មាត្រា ២.២ ) ។

គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីគួរអនុម័តច្បាប់ជាតិមួយស្តីពីសិទ្ធិជនពិការ ។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីបញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននូវព័ត៌មានលំអិតអំពីជនពិការ ដោយបញ្ចូលទាំងកុមារនិងស្ត្រីក្នុងនោះផងដែរ ពាក់ព័ន្ធនឹងការទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ ។

១៨. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់យ៉ាងខ្លាំងថា ទោះបីជាមានច្បាប់ និង វិធានការផ្សេងៗរបស់រដ្ឋភាគី ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីក្តី ក៏ការបែងចែកយ៉េនឌ័រនៅតែមានក្នុងសង្គមកម្ពុជា ដោយរួមទាំងការអនុវត្តន៍ជាប្រពៃណី ដូចមានក្នុងច្បាប់ស្រី *(Women's Code)* ដែលនៅតែជាផ្នែកមួយនៃកម្មវិធីអប់រំនៅកំរិតបឋមសិក្សា ហើយដែលដាក់តួនាទីរបស់ស្ត្រីឲ្យស្ថិតនៅទាបជាងបុរស ។ ចរិតនៃការបែងចែកនេះទទួលស្គាល់តំលៃរបស់ស្ត្រីត្រឹមតែការងារក្នុងផ្ទះ តែមិនទទួលស្គាល់ការងាររបស់ស្ត្រីនៅក្នុងសង្គមឡើយ ដូច្នេះ នេះជាការដកហូតពីស្ត្រីនូវការទទួលបានយ៉ាងពេញលេញនូវសិទ្ធិដែលមានចែងក្នុងកតិកាសញ្ញានេះ ( មាត្រា ២.២) ។

គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំង សូមឲ្យរដ្ឋភាគីដក *ច្បាប់ស្រី (Women's Code)* ចេញពីកម្មវិធីអប់រំនៅកំរិតបឋមសិក្សា ហើយដាក់ជំនួសវិញដោយឧបករណ៍អប់រំដែលលើកស្ទួយតំលៃស្ត្រីទាំងនៅក្នុងផ្ទះ ទាំងនៅក្នុងសង្គម ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ផងដែរថា រដ្ឋភាគីគួរចាត់វិធានការ ដើម្បីអនុវត្តច្បាប់របស់ខ្លួនស្តីពីការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងធ្វើយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន និងកម្មវិធីផ្សព្វផ្សាយការយល់ដឹង ដើម្បីលុបបំបាត់ចរិតអួតអាង និងការអនុវត្តន៍ទាំងឡាយណាដែលដាក់តួនាទីរបស់ស្ត្រីឲ្យស្ថិតនៅទាបជាងបុរស ។

១៩. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ថា ទន្ទឹមនឹងការរាលដាលនៃជម្ងឺហ៊ីវ/អេដស៍នៅក្នុងរដ្ឋភាគីមានការថយចុះក្តី ក៏មានសេចក្តីរាយការណ៍ថា ចំនួនស្ត្រីដែលឆ្លងជម្ងឺនេះពីដៃគូរបស់ខ្លួន មានការកើនឡើង ហើយថានៅក្នុងឆ្នាំ២០០៦ មានអ្នកផ្ទុកមេរោគហ៊ីវ/អេដស៍ចំនួន៥២ ភាគរយគឺជាស្ត្រី ។ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ផងដែរថា ទោះបីជារដ្ឋភាគីមានគំនិតផ្តួចផ្តើមហើយក្តី ក៏សមត្ថភាពនៅមានកំរិតនិងមានកង្វះខាតថវិកា និងធនធានដែលមានទិសដៅជាក់លាក់សំរាប់កម្មវិធីដែលផ្តោតលើស្ត្រី (មាត្រា ២.២ និងមាត្រា ១២ ) ។

គណៈកម្មាធិការផ្តល់ជាអនុសាសន៍ដល់រដ្ឋភាគីគួរដោះស្រាយបញ្ហានៃការបែងចែកអវិជ្ជមានដែលធ្វើឲ្យស្ត្រីរិតតែងាយរងគ្រោះថែមទៀត ដោយសារជម្ងឺហ៊ីវ/អេដស៍ និងជំរុញឲ្យមានការចូលរួមពីបុរសក្នុងកម្មវិធីទាំងឡាយ ដែលផ្តល់ព័ត៌មានអំពីសិទ្ធិខាងផ្លូវភេទ និងសិទ្ធិខាងការបន្តពូជ ។ គណៈកម្មាធិការគូសបញ្ជាក់អំពីសារៈសំខាន់នៃការធ្វើឲ្យមន្ត្រីប្រតិបត្តិច្បាប់ និងអ្នកឯទៀត ដែលមានតួនាទីនៃអំណាច យល់ដឹងអំពីច្បាប់ តាមរយៈការរៀបចំឲ្យមានកម្មវិធីផ្តល់ព័ត៌មានមានប្រសិទ្ធថែមទៀតដល់ពួកគាត់ ។

២០. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ធ្ងន់ធ្ងរថា ទោះបីជាមានការខិតខំប្រឹងប្រែងពីរដ្ឋភាគីក្តី ក៏កំរិតនៃអំពើហឹង្សាលើស្ត្រីភេទ និងកុមារីនៅតែមានកំរិត ហើយថាបាតុភាពនេះមានទំនោរទៅរកភាពជាប់ទាក់ទងគ្នាក្នុងកំរិតខ្ពស់នៃអំពើហឹង្សាទូទៅ ជាមួយនឹងអសមភាពយ៉ាងខ្លាំងផ្នែកយ៉េនឌ័រ ។ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ថា ឧប្បត្តិហេតុនៃអំពើហឹង្សាខាងយ៉េនឌ័រ ការរំលោភផ្លូវភេទគឺកើតចេញឥរិយាបទខាងយ៉េនឌ័រ ដែលទំលាក់កំហុសទៅលើស្ត្រីរងគ្រោះ ហើយថាការដោះស្រាយចំពោះជនរងគ្រោះដោយអំពើហឹង្សាប្រឆាំងនឹងស្ត្រី គឺនៅមានកំរិត ។ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ទៀតថា ការការពារតាមផ្លូវច្បាប់ត្រូវបានរាំងស្ទះដោយសារការអនុវត្តន៍គ្មានប្រសិទ្ធភាពនៃច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារ ហើយការផ្តន្ទាទោសព្រហ្មទណ្ឌលើករណីនេះគឺកម្រមានណាស់(មាត្រា ៣ និងមាត្រា ១០ ) ។

គណៈកម្មាធិការស្នើយ៉ាងទទូចឲ្យរដ្ឋភាគីអនុវត្តយ៉ាងម៉ឺងម៉ាត់ និងផ្តន្ទាទោសចំពោះជនដែលល្មើសនឹងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងក្រមព្រហ្មទណ្ឌ និងអនុវត្តឲ្យបានពេញលេញនូវផែនការសកម្មភាព ដើម្បីបង្ការអំពើហិង្សាប្រឆាំងនឹងស្ត្រី ។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីយកចិត្តទុកដាក់ចំពោះសេចក្តីផ្តល់មតិទូទៅលេខ១៦ របស់ខ្លួន ស្តីពីសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីក្នុងការទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ហើយស្នើឲ្យរដ្ឋភាគីបញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន នូវព័ត៌មានលំអិតអំពីសមិទ្ធិផលដែលសំរេចបានក្នុងបញ្ហានេះ ។

២១. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ អំពីកំណើនខ្ពស់នៃអត្រាអ្នកអត់ការងារធ្វើ និងការងារមានប្រាក់ឈ្នួលទាបនៅក្នុងរដ្ឋភាគី ជាពិសេសក្នុងចំណោមមនុស្សវ័យក្មេងជាច្រើននាក់ដែលត្រូវការឱកាសការងារនិងមុខជំនាញសមស្រប ។ ក្នុងករណីនេះ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ថា ការបណ្តុះបណ្តាលវិជ្ជាជីវៈមិនបានគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការនៃការរីកចំរើនផ្នែកសេដ្ឋកិច្ច និងគំលាតដ៏ធំរវាងការផ្តល់ជំនាញ និងតម្រូវការខាងការងារ ។ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ផងដែរ អំពីការវាយតំលៃក្នុងរបាយការណ៍ឆ្នាំ២០០៧របស់UNDP/ILO និងសេចក្តីព្រាងរបស់អង្គការសហប្រជាជាតិវិភាគអំពីស្ថានភាពយុវជន ឆ្នាំ២០០៩ ថា យុវជន ៣០០.០០០ នាក់ ចូលទីផ្សារការងាររៀងរាល់ឆ្នាំ ហើយថាតួលេខនេះនឹងកើនឡើងដល់ ៤០០.០០០ នាក់ នាពេលដ៏ខ្លីខាងមុខ ដូច្នេះវាធ្វើឲ្យមានការពិបាកសំរាប់រដ្ឋភាគីក្នុងការស្រូបយកអ្នកស្វែងរកការងារថ្មីទាំងនេះ (មាត្រា ៦ )

គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីគួរពិនិត្យឡើងវិញនូវគោលនយោបាយការងាររបស់ខ្លួន និងបង្កើតផែនការយុទ្ធសាស្ត្រស្តីពីការងារ ដើម្បីលើកកំពស់ការងាររបស់យុវជន ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ដែរ ឲ្យរដ្ឋភាគីពិនិត្យឡើងវិញអំពីយុទ្ធសាស្ត្របណ្តុះបណ្តាលក្នុងគោលដៅធានាការអប់រំវិជ្ជាជីវៈ និងបច្ចេកទេស ដើម្បីឆ្លើយតបនឹងតម្រូវការការងារ ដោយមានការពិគ្រោះយោបល់ជាមួយកម្មករ និងអង្គការនិយោជកនានា ព្រមទាំងស្ថាប័នជាដៃគូក្នុងស្រុក ។

២២. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ អំពីការនៅតែមានភាពមិនស្មើគ្នានៃប្រាក់ឈ្នួលសំរាប់ការងារដែលមានតំលៃស្មើគ្នា រវាងបុរសនិងស្ត្រី នៅក្នុងការអនុវត្តន៍ជាក់ស្តែង (មាត្រា ៧ )

គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងដល់រដ្ឋភាគីថា គោលការណ៍នៃប្រាក់ឈ្នួលស្មើគ្នាសំរាប់ការងារដែលមានតំលៃស្មើគ្នា រវាងបុរសនិងស្ត្រី គួរតែបានឆ្លុះបញ្ចាំងយ៉ាងពេញលេញ និងយ៉ាងច្បាស់លាស់នៅក្នុងច្បាប់មួយ ហើយច្បាប់នោះទៀតសោធ ក៏គួរតែបានអនុវត្តយ៉ាងម៉ឺងម៉ាត់បំផុត ហើយត្រូវចាត់វិធានការច្បាស់លាស់ និងមានប្រសិទ្ធភាពក្នុងបញ្ហានេះ ។

២៣. គណៈកម្មាធិការមានកង្វល់អំពីប្រាក់ឈ្នួលអប្បរមាដែលអនុវត្តតែទៅលើវិស័យកាត់ដេរ ហើយមិនអនុវត្តទៅលើវិស័យឯទៀត ហើយថាប្រាក់ឈ្នួលអប្បរមាមិនអាចឲ្យកម្មករ និងក្រុមគ្រួសាររបស់ពួកគេមានជីវភាពរស់នៅសមរម្យឡើយ (មាត្រា ៧ )

**គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីគួរកំណត់ប្រាក់ឈ្នួលអប្បបរិមាជាលក្ខណៈទូទៅមួយ ដែល អាចឲ្យកម្មករទាំងអស់ និងក្រុមគ្រួសាររបស់ពួកគាត់ មានកំរិតជីវភាពរស់នៅសមរម្យ ។**

២៤. គណៈកម្មាធិការមានកង្វល់ធ្ងន់ធ្ងន់អំពីឃាដកម្មលើរូបលោក ជា វិជ្ជា លោក រស់ សុវណ្ណារ៉េត និងលោក ហ៊ី វុទ្ធី ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ការគំរាមសំលាប់មេដឹកនាំសហជីពឯទៀត ការខកខានមិនបានស៊ើបអង្កេតករណីឃាដកម្ម និងការគំរាមសំលាប់ និងការនាំខ្លួនជនល្មើសពិតប្រាកដទៅតុលាការដើម្បីផ្តន្ទាទោសទៅតាមច្បាប់ នាំឲ្យមានបរិយាកាសនិទណ្ឌភាពនៅក្នុងប្រទេស ។ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ អំពីរបាយការណ៍របស់ក្រុមបេសកកម្មនៃអង្គការពលកម្មអន្តរជាតិ(ILO)មកកាន់កម្ពុជា ក្នុងឆ្នាំ ២០០៨ បញ្ជាក់ថា តុលាការកម្ពុជា ត្រូវបានញាំញីធ្ងន់ធ្ងន់ដោយបញ្ហាសមត្ថភាព និងការខ្វះភាពឯករាជ្យ ហើយថា ការកាត់ទោសលោក ប៊ន សំណាង និងលោក សុខ សំអឿនពីបទឃាតកម្មលើលោក ជា វិជ្ជា ប្រធានសហជីពកម្មករ បានធ្វើឡើងក្នុងសវនាការមួយដែលគេសំគាល់ឃើញមានភាពមិនប្រក្រតីផ្នែកនីតិវិធី រួមទាំង ភាពស្ទាក់ស្ទើរក្នុងការទទួលយកភស្តុតាងអំពីភាពគ្មានទោសពៃរបស់ពួកគាត់ និងបានសំរេចឲ្យលោក ថាច់ សារេត ជាប់ពន្ធនាគាររយៈពេល ១៥ ឆ្នាំ ពីបទធ្វើឃាតប្រធានសហជីព លោក រស់ សុវណ្ណារ៉េត ហើយរដ្ឋភាគីមិនបានបង្ហាញពីវិធានការជាក់លាក់ណាមួយ ដែធានាឲ្យមានការពិនិត្យឡើងវិញដោយឯករាជ្យ និងមានអត្ថន័យចំពោះករណីទាំងឡាយដែលមិនទាន់ដោះស្រាយ ។ របាយការណ៍របស់អង្គការ ILO បានកត់សំគាល់ដោយកង្វល់ដែរថា ខ្លួនមិនបានទទួលព័ត៌មានណាមួយ អំពីការរីកចំរើនក្នុងការស៊ើអង្កេតករណីលោក ហ៊ី វុទ្ធី ហើយថាមានការខុសឆ្គោយខាងយុត្តិធមិ ក្នុងការចោទប្រកាន់មនុស្សខុសអំពីបទឃាដកម្ម ដែលជនល្មើសពិតប្រាកដបានគេចខ្លួន និងគ្មានការផ្តន្ទាទោស (មាត្រា ៨)

**គណៈកម្មាធិការបញ្ជាក់យ៉ាងច្បាស់ថាសិទ្ធិរបស់កម្មករ ដូចមានចែងក្នុងមាត្រា៨ នៃកតិកាសញ្ញានេះ អាចត្រូវបានប្រើតែក្នុងបរិយាកាសមួយដែលគ្មានអំពើហិង្សា ការគាបសង្កត់ ឬការគំរាមកំហែងតាមបែបណាក៏ដោយ ។ គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យចាត់វាល់វិធានការចាំបាច់ដូចដែលបានស្នើដោយគណៈកម្មាធិការទទួលបន្ទុកសេរីភាពខាងសមាគមនៃអង្គការ ILO ដើម្បីធានាថា សិទ្ធិខាងសហជីពរបស់កម្មករនៅកម្ពុជា ត្រូវបានគោរពយ៉ាងពេញលេញ ហើយថាសមាជិកសហជីពកម្មករទាំងអស់ អាចធ្វើសកម្មភាពរបស់ខ្លួនក្នុងបរិយាកាសមួយដែលគ្មានការបំភិតបំភ័យ និងហានិភ័យចំពោះសន្តិសុខផ្ទាល់ខ្លួន និងជីវិតរបស់ពួកគាត់ ។ គណៈកម្មា-**

ធិការស្នើឲ្យរដ្ឋភាគីស្វែងរកកិច្ចសហការផ្នែកបច្ចេកទេសពីអង្គការILO ជាពិសេសក្នុងវិស័យនៃការពង្រឹងសមត្ថភាពស្ថាប័ន ក៏ដូចជា ក្នុងការបង្កើតតុលាការការងារ និងការពិនិត្យឡើងវិញនៃច្បាប់ស្តីពីសហជីព ។ គណៈកម្មាធិការស្នើផងដែរ ឲ្យរដ្ឋភាគីបញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននូវផ្តល់ព័ត៌មានថ្មីៗលំអិតអំពីបញ្ហានេះ ។

២៥. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ថា បើទោះជាមានការខិតខំប្រឹងប្រែងរបស់រដ្ឋភាគីក្តី ពលកម្មកុមារនៅតែជាបញ្ហាមួយធ្ងន់ធ្ងរក្នុងប្រទេសនេះ ។ គណៈកម្មាធិការមានកង្វល់ជាពិសេសថា ច្បាប់ដែលហាមប្រាមពលកម្មកុមារមិនត្រូវបានអនុវត្ត សូម្បីតែនៅក្នុងវិស័យការងារផ្លូវការក្តី ហើយថា កុមារនៅតែងាយរងគ្រោះដោយរាល់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ រួមទាំងពលកម្មកុមារដោយបង្ខំ ឬជាកាតព្វកិច្ច និងការធ្វើអាជីវកម្មពាណិជ្ជកម្មផ្លូវភេទ (មាត្រា ១០ )

គណៈកម្មាធិការស្នើយ៉ាងទទូចឲ្យរដ្ឋភាគីបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ និងការពារកុមារពីរាល់ទម្រង់នៃការធ្វើអាជីវកម្មខាងសេដ្ឋកិច្ច និងអាជីវកម្មផ្លូវភេទ ដោយរួមទាំងទម្រង់ដែលអាក្រក់បំផុតនៃពលកម្មកុមារ ក្នុងចំណោមអាជីវកម្មឯទៀត តាមរយៈការពង្រឹងច្បាប់ជាតិរបស់ខ្លួនដែលហាមប្រាមពលកម្មកុមារ ស្របតាមបទដ្ឋានអន្តរជាតិ ដោយបង្កើនចំនួនអធិការកិច្ចការងារ ដើម្បីធានាការគោរពច្បាប់ជាតិរបស់ខ្លួន ដែលហាមប្រាមពលកម្មកុមារ ធានាឲ្យមានការពិន័យជាប្រាក់ និងការដាក់ទោសព្រហ្មទណ្ឌ ចំពោះជនទាំងឡាយណាដែលឆ្លៀតទាញយកប្រយោជន៍ពីពលកម្មកុមារដោយខុសច្បាប់ រៀបចំឲ្យមានការបណ្តុះបណ្តាលជាកាតព្វកិច្ចដល់មន្ត្រីប្រតិបត្តិច្បាប់ ព្រះរាជអាជ្ញា និង ចៅក្រម និងអនុម័តវិធានការចាំបាច់ ដើម្បីសម្រួលដល់ការស្តារនីតិសម្បទា និងការទទួលបានឱកាសអប់រំសំរាប់អតីតកម្មករកុមារទាំងនោះ ។

២៦. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ធ្ងន់ធ្ងរ អំពីរបាយការណ៍ថា មានស្ត្រី និងកុមារប្រមាណជា៤០០ - ៨០០ នាក់ ក្នុងមួយខែ ត្រូវបានគេជួញដូរទៅក្រៅប្រទេស ដើម្បីបំរើផ្លូវភេទ ហើយថា បើទោះជាមានវិធានការច្បាប់ រដ្ឋបាល និងគោលនយោបាយមួយចំនួនត្រូវបានអនុម័តដោយរដ្ឋភាគី ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សហើយក្តី ក៏ចំនួនស្ត្រី និងកុមារដែលត្រូវគេជួញដូរទៅក្រៅប្រទេស និងក្នុងប្រទេសសំរាប់គោលបំណងនៃការជួញដូរផ្លូវភេទ និងការងារដោយបង្ខំ មានការកើនឡើងខ្ពស់ ។ គណៈកម្មាធិការមានកង្វល់ថា ការផ្តន្ទាទោស និងការកាត់ទោសអ្នកជួញដូរមនុស្ស មានចំនួនទាបនៅឡើយ (មាត្រា ១០) ។

គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ សំរាប់គោលបំណងធ្វើអាជីវកម្មផ្លូវភេទ និងការងារដោយបង្ខំ ក្នុងចំណោមការធ្វើអាជីវកម្មឯទៀត តាមរយៈការផ្តន្ទាទោស និងការកាត់ទោសជនដែលល្មើសនឹងច្បាប់ប្រឆាំងការជួញដូរមនុស្ស តាមរយៈការគាំទ្រកម្មវិធី និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ដើម្បីបង្ការការជួញដូរមនុស្ស ដោយរៀបចំឲ្យមានការបណ្តុះបណ្តាលជាកាតព្វកិច្ចដល់មន្ត្រី ប្រតិបត្តិច្បាប់ ព្រះរាជអាជ្ញា និងចៅក្រម ស្តីពីច្បាប់ប្រឆាំងការជួញដូរមនុស្ស និងបង្កើនការផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងច្បាប់ ដល់ជនរងគ្រោះ ។

២៧. គណៈកម្មាធិការមានកង្វល់យ៉ាងខ្លាំងថា ប្រហែលជា ៣៦ % នៃប្រជាជនក្នុងរដ្ឋភាគីរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ហើយមិនអាចទទួលបានតាមបទដ្ឋាននៃអង្គការសុខភាពពិភពលោក ស្តីពីរបបកាឡូរី (Caloric intake) ហើយថា បើទោះជាមានការរីកចំរើនផ្នែកសេដ្ឋកិច្ចក្នុងរដ្ឋភាគីក្តី ក៏ការចំណាយថវិកាជាតិទៅលើសេវាកម្មសង្គម ដូចជា ផ្ទះសម្បែង សុខភាព និងអប់រំ នៅមានកំរិតទាប ។ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ផងដែរ អំពីភាពខុសគ្នាមានគំលាតធំ នៅតាមតំបន់នៃខេត្តផ្សេងៗដែលសេដ្ឋកិច្ចមានការរីកចំរើនតិចនិងដែលគេមិនសូវគិតគូរ និងការខ្វះសមភាពមានគំលាតធំ ក្នុងការបែងចែកចំណូលជាពិសេស រវាងទីក្រុង និងតំបន់ជនបទ ដែលប្រជាជនភាគច្រើនរស់នៅក្នុងភាពក្រីក្រ (មាត្រា ១១)

គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីយកចិត្តទុកដាក់ចំពោះសេចក្តីថ្លែងការណ៍របស់ខ្លួនស្តីពី " ការវាយតំលៃអំពីកាតព្វកិច្ចចាត់វិធានការជា ' អតិបរមានៃធនធានដែលមានរបស់ខ្លួន ' ក្រោមពិធីសារបន្ថែមនៃកតិកាសញ្ញា " (E/C.12/2007/1) ហើយផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីគួរបង្កើនការចំណាយថវិកាជាតិរបស់ខ្លួនទៅលើសេវា និងការជួយឧបត្ថម្ភផ្នែកសង្គមកិច្ច ដូចជា ផ្ទះសម្បែង ស្បៀងអាហារ សុខភាព និងការអប់រំ ដើម្បីស្របតាមមាត្រា២ កថាខ័ណ្ឌទី១ ឲ្យសំរេចបានជាបណ្តើរៗនូវសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលមានចែងក្នុងកតិកាសញ្ញានេះ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថែមទៀតថា រដ្ឋភាគីគួរលៃបំរុងធនធានគ្រប់គ្រាន់សំរាប់ការអនុវត្តន៍យុទ្ធសាស្ត្ររបស់ខ្លួន ស្តីពីការកាត់បន្ថយភាពក្រីក្រ និងធានាការធ្វើសមាហរណកម្មយ៉ាងពេញទំហឹងនូវសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ទៅក្នុងយុទ្ធសាស្ត្រនោះ ដូចដែលគណៈកម្មាធិការបានផ្តល់ជាអនុសាសន៍ក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនស្តីពី " ភាពក្រីក្រ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ " (E/C.12/2001/10) ។

២៨. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ធ្ងន់ធ្ងរថា តាមការសិក្សាមួយក្នុងឆ្នាំ២០០៨ ស្តីពីតំលៃម្ហូបអាហារ គឺប្រមាណជា ១២ ភាគរយនៃគ្រួសារ ឬមនុស្សប្រមាណជា ១.៧ លាននាក់ មានបញ្ហាអសន្តិសុខស្បៀង ហើយដែលប៉ះពាល់ខ្លាំងបំផុតដោយសារតែការឡើងថ្លៃខ្ពស់នៃតំលៃម្ហូបអាហារ ហើយថាតួលេខនេះអាចនឹងឡើងដល់ ២.៨ លាន នាក់ នៅក្នុងអំឡុងពេលមុនរដូវច្រូតកាត់ប្រមូលផល (មាត្រា ១១)

**គណៈកម្មាធិការផ្តល់ជាអនុសាសន៍ដល់រដ្ឋភាគីឲ្យពង្រឹងយុទ្ធសាស្ត្រអន្តរាគមន៍របស់ខ្លួន ក្នុងការឆ្លើយតបទៅនឹងស្ថានការណ៍អាសន្ននៃការកើនឡើងនូវបញ្ហាអសន្តិសុខស្បៀង ។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីបញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននូវព័ត៌មានលំអិតអំពីលទ្ធផលនៃយុទ្ធសាស្ត្រអន្តរាគមន៍ទាំងនេះ ។**

២៩. គណៈកម្មាធិការមានកង្វល់ជាខ្លាំងអំពីការនៅតែអូសបន្លាយពេលវេលា ក្នុងការអនុម័តគោលនយោបាយជាតិស្តីពីផ្ទះសម្បែង នៅក្នុងរដ្ឋភាគី និងអំពីថាមានអ្នកក្រុងជាច្រើននាក់រស់នៅតាមសំណង់ក្រីក្រ គ្មានផ្ទះសម្បែងត្រឹមត្រូវ (មាត្រា ១១ )

**គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីអនុម័ត ជាបញ្ហាអាទិភាព នូវគោលនយោបាយជាតិស្តីពីផ្ទះសម្បែង ដែលលើកកំពស់ប្រជាជនក្រីក្ររស់នៅទីក្រុង និងធានាសុវត្ថិភាពកាន់កាប់ដីធ្លីផ្ទះសម្បែង ដែលត្រូវមានស្ថាប័នច្បាស់លាស់ទទួលខុសត្រូវអនុវត្តការងារនេះ នៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន និងផ្តល់ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីឲ្យការអនុវត្តន៍នេះមានប្រសិទ្ធភាព ។**

៣០. គណៈកម្មាធិការមានកង្វល់ជាខ្លាំងអំពីរបាយការណ៍ថា ចាប់ពីឆ្នាំ២០០០ មក មានប្រជាជនជាង ១០០.០០០ នាក់ ត្រូវបានបណ្តេញចេញ នេះគិតតែនៅទីក្រុងភ្នំពេញមួយគត់ ហើយមានយ៉ាងតិចណាស់ក៏ ១៥០.០០០ នាក់ដែរ ដែលបន្តស្ថិតក្រោមការគំរាមបណ្តេញចេញដោយបង្ខំ ហើយថាអាជ្ញាធរនៃរដ្ឋភាគីបានចូលរួមយ៉ាងសកម្មក្នុងការដណ្តើមយកដីធ្លី ។ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ជាខ្លាំងថា អាត្រានៃការបណ្តេញចេញដោយបង្ខំក្នុងទ្រង់ទ្រាយធំ មានការកើនឡើងក្នុងរយៈពេលជាង១០ឆ្នាំកន្លងមកនេះ ដោយសារតែកំណើននៃការងារសាធារណៈ គំរោងរៀបចំសោភណ្ឌភាពទីក្រុង ការអភិវឌ្ឍន៍ទីក្រុងជាឯកជន ការលក់ទិញដីធ្លី និងការផ្តល់សម្បទានលើផ្ទៃដីដ៏ធំសម្បើមឲ្យទៅក្រុមហ៊ុនឯកជននានា ។ គណៈកម្មាធិការមានកង្វល់ផងដែរ អំពីការខ្វះការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាព និងការដោះស្រាយត្រឹមត្រូវនិងមានប្រសិទ្ធភាពតាមផ្លូវច្បាប់ ចំពោះបុគ្គលទាំងឡាយដែលរងផលប៉ះពាល់ដោយការបណ្តេញចេញ ព្រមទាំង មិនមានវិធានការគ្រប់គ្រាន់ ដើម្បីផ្តល់សំណងត្រឹមត្រូវ ឬកន្លែងសមស្របសំរាប់ការតាំងលំនៅថ្មីដល់គ្រួសារទាំងឡាយ ដែលត្រូវគេបង្ខំឲ្យចាកចេញពីដីធ្លីរបស់

ខ្លួន ។ គណៈកម្មាធិការមានកង្វល់ ផងដែរអំពីរបាយការណ៍ ថាមានអំពើហឹង្សាកើតមានក្នុងពេលធ្វើការបណ្តេញចេញ ដែលករណីខ្លះត្រូវបានធ្វើឡើងដោយនគរបាល ។ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ជាខ្លាំងអំពីឧទាហរណ៍ ដែលបានគូសបញ្ជាក់នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៩ ដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ អំពីការដែលនឹងមានការបណ្តេញប្រជាពលរដ្ឋក្នុង " ក្រុមទី៧៨ " ដែលពួកគាត់មានជំលោះផ្លូវច្បាប់អំពីកម្មសិទ្ធិដីធ្លីរបស់ខ្លួនតាំងពីឆ្នាំ២០០៤ មកម្ល៉េះ ក៏ដូចជាការបណ្តេញ ចេញដោយបង្ខំ និងការគំរាមកំហែងនៅភូមិសំបុកចាបសង្កាត់ទន្លេបាសាក់ សង្កាត់មិត្តភាព ក្រុងព្រះសីហនុ បឹងកក់ ដីក្រហម និង បូរីកីឡា រាជធានីភ្នំពេញ និងក្នុងចំណោមករណីផ្សេងទៀត (មាត្រា ១១)

គណៈកម្មាធិការស្នើយ៉ាងទទូចឲ្យរដ្ឋភាគីធ្វើការផ្អាកជាបណ្តោះអាសន្ននូវរាល់ការបណ្តេញចេញរហូតដល់មានក្របខ័ណ្ឌច្បាប់ត្រឹមត្រូវ និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានបញ្ចប់ដើម្បីធានាការការពារសិទ្ធិមនុស្សនៃប្រជាជនកម្ពុជាគ្រប់រូប ដោយរួមទាំងជនជាតិដើមភាគតិចផងដែរ ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ឲ្យរដ្ឋភាគីធ្វើការពិគ្រោះយោបល់ជាបន្ទាន់ជាមួយស្ថាប័នជាដៃគូនានា ដើម្បីឈានទៅបំពេញនិយមន័យនៃពាក្យ "ផលប្រយោជន៍សាធារណៈ" ដូចមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ និងបង្កើតគោលការណ៍ណែនាំមួយច្បាស់លាស់សំរាប់ការបណ្តេញចេញ ប្រសិនជាអាចមាន ។ គណៈកម្មាធិការស្នើយ៉ាងទទូចផងដែរឲ្យរដ្ឋភាគីកំណត់ព្រំប្រទល់ឲ្យបានច្បាស់លាស់រវាងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ។ ដោយចាត់ទុកជាបញ្ហាអាទិភាព គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងថា រដ្ឋភាគីធ្វើការពិគ្រោះយោបល់ជាចំហរ ដោយមានការចូលរួម និងប្រកបដោយអត្ថន័យជាមួយអ្នកភូមិ និងសហគមន៍នានាដែលរងផលប៉ះពាល់ជាមុន មុននឹងអនុវត្តគំរោងអភិវឌ្ឍន៍និងគំរោងរៀបចំទីក្រុងជាថ្មី ហើយត្រូវធានាថា បុគ្គលទាំងឡាយដែលត្រូវបានបណ្តេញចេញដោយបង្ខំពីដីរបស់ខ្លួន ត្រូវបានផ្តល់សំណងសមរម្យ និងឬ ផ្តល់ជូនគាត់នូវទីតាំងថ្មីស្របតាមគោលការណ៍ណែនាំដែលបានអនុម័តដោយគណៈកម្មាធិការក្នុងសេចក្តីផ្តល់មតិទូទៅរបស់ខ្លួនលេខ៧ (១៩៩៧) ស្តីពីការបណ្តេញចេញដោយបង្ខំ និងធានាថា ទីតាំងថ្មី ត្រូវផ្តល់ឲ្យមានសេវាមូលដ្ឋានផ្សេងៗ រួមទាំងទឹកផឹកភ្លើងអគ្គីសនី សំភារៈសំរាប់ដុសសំអាត និងអានាម័យគ្រប់គ្រាន់ ព្រមទាំងសេវាឯទៀត រួមមានសាលារៀន មណ្ឌលគាំពារសុខភាព និងមធ្យោបាយដឹកជញ្ជូននៅពេលធ្វើការតាំងលំនៅថ្មី ។ គណៈកម្មាធិការទាញចំណាប់អារម្មណ៍ផងដែរដល់រដ្ឋភាគី ចំពោះគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការធ្វើចំនាកស្រុកផ្អែកលើការអភិវឌ្ឍន៍ (UN Doc. No. A/HRC/4/18) ដែលបានរៀបចំដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីសិទ្ធិមានលំនៅដ្ឋានសមរម្យ ។

៣១.	គណៈកម្មាធិការសំដែងកង្វល់របស់ខ្លួនយ៉ាងខ្លាំងអំពីវប្បធម៌ហឹង្សា និងនិទណ្ឌភាពដែលមានជាទូទៅក្នុងរដ្ឋភាគី និងការគាបសង្កត់ទៅលើសកម្មជនសិទ្ធិមនុស្សដែលការពារសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ជាពិសេស អ្នកដែលការពារសិទ្ធិខាងលំនៅដ្ឋាន និងដីធ្លី ។ គណៈកម្មាធិការមានកង្វល់ផងដែរអំពីរបាយការណ៍ថា ប្រព័ន្ធតុលាការ ត្រូវបានគេប្រើប្រាស់ ដើម្បីផ្តល់ភាពស្របច្បាប់ដល់ការបណ្តេញចេញដោយបង្ខំ និងការចោទប្រកាន់ខុសទៅលើសកម្មជនការពារសិទ្ធិខាងលំនៅដ្ឋាន (មាត្រា ១១)

> គណៈកម្មាធិការស្នើយ៉ាងទទូចឲ្យរដ្ឋភាគីចាត់វាល់វិធានការចាំបាច់ ដើម្បីប្រយុទ្ធប្រឆាំងនឹងវប្បធម៌ហឹង្សា និងនិទណ្ឌភាពដែលកើតមានជាទូទៅក្នុងរដ្ឋភាគី និងការពារសកម្មជនសិទ្ធិមនុស្ស រួមទាំងតំណាងជនជាតិដើមភាគតិច សកម្មជនកសិករ ដែលបានចូលរួមក្នុងការការពារសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សហគមន៍ខ្លួន ប្រឆាំងនឹងការបំភិតបំភ័យ ការគំរាមកំហែង និងអំពើហឹង្សា ទោះជាអំពើទាំងនោះត្រូវបានប្រព្រឹត្តដោយកងកំលាំង និងភ្នាក់ងារសន្តិសុខរដ្ឋ ឬដោយតួអង្គមិនមែនរដ្ឋក្តី ។ គណៈកម្មាធិការអំពាវនាវផងដែរដល់រដ្ឋភាគីឲ្យធានាថា រាល់ករណីដែលបានចោទប្រកាន់អំពីការគាបសង្កត់ និងការរំលោភទាំងប៉ុន្មាន ត្រូវតែបានធ្វើការស៊ើបអង្កេតទាំងស្រុង និងយ៉ាងឆាប់រហ័ស ហើយថាជនដែលគេអះអាងថាជាជនដៃដល់ត្រូវតែចោទប្រកាន់ និងផ្តន្ទាទោសទៅតាមច្បាប់ ប្រសិនជារកឃើញថាពិតជាមានពិរុទ្ធភាពមែននោះ ។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់នៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននូវព័ត៌មានលំអិតអំពីសមិទ្ធិផលដែលសំរេចបានក្នុងការបង្ការ និងការផ្តន្ទាទោសចំពោះការគាបសង្កត់ និងអំពើរំលោភផ្សេងៗ ។

៣២.	គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ជាខ្លាំងថា អត្រាមរណៈនៃមាតានៅក្នុងរដ្ឋភាគីនៅតែដដែលមិនមានការប្រែប្រួល ហើយថារដ្ឋភាគីមិនស្ថិតនៅលើផ្លូវមួយឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់ខ្លួនឆ្នាំ២០១៥ ឡើយ ហើយអត្រានៃការសំរាលកូននៅមណ្ឌលសុខភាពនានាមានកំរិតទាបត្រឹម ២២ ភាគរយ ក្នុងឆ្នាំ២០០៥ ដោយសារតែឧបសគ្គមួយចំនួន ដូចជា ថ្លៃឈ្នួលខ្ពស់ កង្វះខាតពេទ្យឆ្មប និងមកពីមណ្ឌលសុខភាពភាគច្រើនមិនបើកបំរើការ ២៤ ម៉ោងក្នុងមួយថ្ងៃ ៧ ថ្ងៃក្នុងមួយសប្តាហ៍ ។ ម្យ៉ាងវិញទៀត គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ថា អាត្រារំលូតកូនមានការកើនឡើង ហើយការរំលូតកូនដែលគ្មានសុវត្ថិភាពគឺជាកត្តាសំខាន់ចំពោះមរណៈភាពនៃមាតា ។ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ដែរថា អត្រាមរណៈនៃទារកដែលទើបនឹងកើតនៅតែមានកំរិតខ្ពស់នៅឡើយ ទោះបីជា រដ្ឋភាគីមានការរីកចំរើនក្នុងការដោះស្រាយបញ្ហាមរណៈភាពនៃទារក និងមរណៈភាពនៃកុមារក្រោម អាយុប្រាំឆ្នាំក្តី (មាត្រា ១២)

គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីពង្រឹងការអនុវត្តន៍ និងតាមឃ្លាំមើលការអនុវត្តន៍គោលនយោបាយដូរវេណ និងការពង្រាយបុគ្គលិកក្រសួងសុខាភិបាល ដើម្បីធានាឲ្យមានពេទ្យឆ្មបនៅតាមមណ្ឌលសុខភាពទាំងអស់នៅទូទាំងប្រទេស និងផ្តល់កន្លែងស្នាក់នៅ និងរបបហូបចុកដល់ពេទ្យឆ្មបទាំងនោះ ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ផងដែរថា រដ្ឋភាគីគួរបង្កើតមណ្ឌលសំរាប់ឲ្យស្ត្រីមានផ្ទៃពោះស្នាក់នៅបណ្តោះអាសន្នមុនពេលសំរាលកូន(MWH) នៅតាមតំបន់ជនបទមណ្ឌលគាំពារមាតានិងទារកនៅតាមសហគមន៍ និងរៀបចំឲ្យមានវគ្គបណ្តុះបណ្តាលជំនាញពេទ្យឆ្មបដល់បុគ្គលិកពេទ្យនានា ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងថា រដ្ឋភាគីគួរលើកកំពស់ការបណ្តុះបណ្តាល និងសេវាកម្មបង្កើតកូន ដោយអនុវត្តយ៉ាងម៉ឺងម៉ាត់នូវច្បាប់ស្តីពីការរំលូតកូន ។

៣៣. គណៈកម្មាធិការមានកង្វល់យ៉ាងខ្លាំងថា រយៈពេលជាច្រើនឆ្នាំនៃភាពវឹកវរ និងអំពើហឹង្សាក្នុងរដ្ឋភាគី បានបណ្តាលឲ្យមានបញ្ហាសុខភាពផ្លូវចិត្តកំរិតខ្ពស់ ហើយមិនបានផ្តល់ការព្យាបាលដល់ប្រជាជនដែលមានបញ្ហាផ្លូវចិត្តឡើយ ។ គណៈកម្មាធិការកត់សំគាល់ដោយភ្ញាក់ផ្អើលអំពីការខ្វះសេវាព្យាបាលសុខភាពផ្លូវចិត្ត ដែលជារឿយៗបណ្តាលឲ្យអ្នកមានជម្ងឺផ្លូវចិត្តត្រូវបានគេដាក់ពន្ធនាគារ មជ្ឈមណ្ឌលព្យាបាលអ្នកញៀនថ្នាំ ឬមជ្ឈមណ្ឌលស្តារនីតិសម្បទាសង្គមកិច្ចដែលផ្តល់សេវាសង្គមកិច្ច ឬដែលផ្តល់សេវាកម្មផ្នែកផ្លូវចិត្តនិងសង្គមមិនបានល្អ និងកន្លែងដែលមានករណីរំលោភ និងកន្លែងដែលបុគ្គលគួរតែទទួលបានកិច្ចគាំពារសុខភាពផ្លូវចិត្ត ត្រូវគេចាប់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ (ពិរុទ្ធជន និងទណ្ឌិត) (មាត្រា ១២)

គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងថា រដ្ឋភាគីពិចារណាអនុម័តច្បាប់ស្តីពីសុខភាពផ្លូវចិត្ត និងអនុម័តផែនការយុទ្ធសាស្ត្រស្តីពីសុខភាពផ្លូវចិត្ត ដែលបញ្ចូលភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល (NGOs) និងស្ថាប័នដៃគូក្នុងវិស័យឯកជននានា ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ផងដែរថា រដ្ឋភាគីធានាថា បុគ្គលទាំងឡាយដែលមានបញ្ហាសុខភាពផ្លូវចិត្ត មិនត្រូវបានបញ្ជូនទៅដាក់ពន្ធនាគារឡើយ ។

៣៤. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ថា ការអប់រំនៅកំរិតបឋមសិក្សាមិនមែនជាកាតព្វកិច្ចទេនៅក្នុងរដ្ឋភាគី បើទោះជាតួលេខនៃអ្នកចុះឈ្មោះចូលរៀននៅកំរិតបឋមសិក្សាមានការកើនឡើងនៅក្នុងរយៈកាលប៉ុន្មានឆ្នាំកន្លងមក និងបានពង្រីកទៅដល់តំបន់ភាគច្រើននៃប្រទេសក្តី ។ គណៈកម្មាធិការកត់សំគាល់ថាការអប់រំកំរិតបឋមសិក្សានៅតែជាបញ្ហាសំរាប់ជនភាគតិចជាតិពន្ធុផ្សេងៗនៅភាគឧត្តរ និងភាគបូព៌ានៃប្រទេស ដែលក្រុមភាគតិចជាតិពន្ធុទាំងនេះនិយាយភាសា ២០ ផ្សេងៗគ្នា ជាភាសាដើមកំណើតរបស់ខ្លួន ចំណែកឯកម្មវិធីអប់រំផ្លូវការមានប្រើតែជាភាសាខ្មែរ ជាការអប់រំនៅកំរិតមធ្យម ។ គណៈកម្មា

ធិការកត់សំគាល់ដោយកង្វល់ដែរថា សហគមន៍ជនជាតិដើមភាគតិចទាំងឡាយអាចបាត់បង់វប្បធម៌ និងភាសារបស់ខ្លួន ដែលសារតែការកង្វះការអប់រំ និងព័ត៌មានជាភាសារបស់ខ្លួនផ្ទាល់ (មាត្រា ១៣ មាត្រា ១៤ និងមាត្រា ១៥)

**គណៈកម្មាធិការផ្តល់ជាអនុសាសន៍ដល់រដ្ឋភាគីឲ្យពង្រីកវិសាលភាពនៃច្បាប់ស្តីពីការអប់រំ ដើម្បីធានាសិទ្ធិអប់រំជាថ្មី ដល់កុមារកម្ពុជាទាំងអស់ដែលភាសាដំបូង (ភាសាដើមកំណើត) របស់ខ្លួន មិនមែនជាភាសាខ្មែរ ។**

៣៥. គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ថា ទន្ទឹមនឹងមានការកើនឡើងនៃប្រាក់បៀវត្សរ៍ និងប្រាក់ឧបត្ថម្ភសំរាប់គ្រូបង្រៀនក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះក្តី ពួកគាត់នៅតែទទួលបានប្រាក់ចំណូលទាបជាងមន្ត្រីរាជការស៊ីវិល ឬបុគ្គលិកគ្មានជំនាញ ។ គណៈកម្មាធិការមានកង្វល់ថា ប្រាក់បៀវត្សរ៍ទាបនេះហើយដែលនាំឲ្យគ្រូបង្រៀនភាគច្រើន ត្រូវតែចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត ដូចជាការងារទីពីរ ដែលធ្វើឲ្យគាត់អវត្តមានជារឿយៗពីថ្នាក់រៀន ជាហេតុនាំឲ្យប៉ះពាល់គុណភាពនៃការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្ស ។ គណៈកម្មាធិការកត់សំគាល់ដោយកង្វល់ថា ប្រាក់បៀវត្សរ៍ទាប ត្រូវបានគេចាត់ថាជាបញ្ហាមួយក្នុងចំណោមបញ្ហាឯទៀត ដែលនាំឲ្យនៅតែមានការប្រមូលយកប្រាក់ឈ្នួលក្រៅផ្លូវការនៅតាមសាលារៀនជាច្រើន (មាត្រា ១៣ មាត្រា ១៤ មាត្រា ១៥)

**គណៈកម្មាធិការផ្តល់ជាអនុសាសដល់រដ្ឋភាគីថា កំណែទម្រង់សេវាសាធារណៈ គួរតែសង្កត់ធ្ងន់ជាពិសេសលើការដំឡើងប្រាក់បៀវត្សរ៍ និងការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់គ្រូបង្រៀន ដោយភ្ជាប់ទៅនឹងការធ្វើចំណាត់ថ្នាក់មុខងារ សិទ្ធិ និងការទទួលខុសត្រូវរបស់គ្រូបង្រៀនផងដែរ ។**

៣៦. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មានលំអិតនៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន អំពីផលប៉ះពាល់នៃកិច្ចព្រមព្រៀងវិនិយោគទុន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេរភាគី និងពហុភាគីរបស់ខ្លួន ទៅលើការទទួលបានសិទ្ធិដែលមានចែងក្នុងបញ្ញត្តិនៃកតិកាសញ្ញានេះ របស់តួអង្គផ្សេងៗនៃសហគមន៍ទាំងឡាយនៅទីក្រុង និងនៅតាមតំបន់ជនបទ នៅទូទាំងប្រទេស (មាត្រា ២.១)

៣៧. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មានលំអិតនៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន អំពីទិន្នន័យលំអិតដែលប្រមូលបានប្រចាំឆ្នាំ ទាក់ទងនឹងបញ្ញត្តិផ្សេងៗនៃកតិកាសញ្ញានេះ ជាឧបករណ៍មួយសំរាប់ធ្វើការវាស់ស្ទង់អំពីការសំរេចបានជាបណ្តើរៗនូវសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (មាត្រា ២.១)

៣៨. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីធានាថាធនធានដែលមានជាអតិបរមាត្រូវបានលៃបំរុងសំរាប់ការការពារនិងការអនុវត្តន៍ឲ្យបាននូវសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ជាពិសេស ចំពោះបុគ្គល ឬក្រុមមនុស្សដែលងាយរងគ្រោះបំផុតនិងដែលគេមិនសូវគិតគូរ ។ គណៈកម្មាធិការជំរុញលើកទឹកចិត្តដល់រដ្ឋភាគីឲ្យបង្កើនតម្លាភាពនិងការទទួលខុសត្រូវ(គណនីភាព) ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍ ដែលបានផ្តល់មូលនីធិដោយម្ចាស់ជំនួយអន្តរជាតិនានា ជាពិសេស សំរាប់កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងស្ថាប័ន និងសំរាប់ការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងភាពក្រីក្រ ។ ក្នុងករណីនេះ គណៈកម្មាធិការសូមទាញចំណាប់អារម្មណ៍របស់រដ្ឋភាគីចំពោះសេចក្តីផ្តល់មតិទូទៅរបស់ខ្លួនលេខ៣ ស្តីពីចរិតលក្ខណៈនៃកាតព្វកិច្ចរបស់រដ្ឋភាគី(E/1991/23) និងសេចក្តីថ្លែងការណ៍របស់ខ្លួន "ការវាយតំលៃអំពីកាតព្វកិច្ចចាត់វិធានការជាអតិបរមានៃធនធានដែលមានរបស់ខ្លួន" ក្រោមពិធីសារបន្ថែមនៃកតិកាសញ្ញានេះ (E/C.12/2007/1) (មាត្រា ២.១)

៣៩. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មានលំអិតនៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន នូវព័ត៌មាន រួមទាំងស្ថិតិបំបែកលំអិតទៅតាមភេទ និងទៅតាមទីក្រុង និងតំបន់ជនបទអំពីវិសាលភាពនៃវិស័យក្រៅផ្លូវការ(ក្រៅប្រព័ន្ធ) ព្រមទាំងគោលនយោបាយផ្សេងៗរបស់រដ្ឋភាគី និងអំពីវិធានការការពារនានា ដែលផ្តោតជាពិសេសទៅលើវិស័យទាំងនេះ (មាត្រា ៦)

៤០. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីពង្រីកវិសាលភាពគ្របដណ្តប់នៃប្រព័ន្ធសុវត្ថិភាពសង្គម តាមរយៈការបង្កើតវិធានការនានាដែលមានគោលដៅដោះស្រាយស្ថានការណ៍របស់បុគ្គល និងក្រុមមនុស្សដែលក្រលំបាកនិងដែលគេមិនសូវគិតគូរ ជាពិសេសជនអានាថានៅក្នុងមណ្ឌលនានានៅទីក្រុង ជនរងគ្រោះដោយការជួញដូរ កុមារអានាថារស់នៅតាមចិញ្ចើមថ្នល់ឬដែលទំនាស់នឹងច្បាប់ និងប្រជាជន និងគ្រួសារក្រីក្រ។ គណៈកម្មាធិការស្នើយ៉ាងទទូចឲ្យរដ្ឋភាគីពិចារណាអំពីការបង្កើតកម្មវិធីជំនួយសង្គមកិច្ចទូទៅមួយ ដើម្បីធានាការទទួលបានសិទ្ធិខាងសន្តិសុខសង្គមសំរាប់ជនគ្រប់រូបនៅក្នុងរដ្ឋភាគី (មាត្រា ៩ មាត្រា ១០ មាត្រា ១១)

៤១. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មានលំអិតនៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន អំពីស្ថានការណ៍នៃកុមារអានាថារស់នៅតាមចញ្ចើមថ្នល់ក្នុងទីក្រុង និងនៅតាមសហគមន៍ជនបទនានា និងអំពីវិធានការផ្សេងៗ ប្រសិនជាមាន ដើម្បីផ្តល់ការការពារ និងការជួយឧបត្ថម្ភដល់កុមារទាំងនោះ (មាត្រា ១០)

៤២. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មានលំអិតនៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន អំពីវិសាលភាពនៃអ្នកគ្មានផ្ទះសម្បែងនៅទូទាំងប្រទេស និងវិធានការនិងកម្មវិធីអន្តរាគមន៍ទាំងឡាយដែលមាន ព្រមទាំងលទ្ធផលនៃការចាត់វិធានការនិងកម្មវិធីអន្តរាគមន៍ទាំងនោះ (មាត្រា ១១)

៤៣. គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីធានាឲ្យមានការលៃបំរុងថវិកាគ្រប់គ្រាន់សំរាប់ការអប់រំនៅគ្រប់កំរិតទាំងអស់ជាពិសេស ការអប់រំកំរិតមូលដ្ឋាន និងតម្លាភាពនៃប្រព័ន្ធបែងចែក និងចំណាយថវិកាសំរាប់ការអនុវត្តន៍សិទ្ធិអប់រំ ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ដែរថា រដ្ឋភាគីគួរពង្រីកកម្មវិធីអប់រំក្រៅប្រព័ន្ធ សំរាប់កុមារីដែលនៅក្រៅសាលារៀន (មាត្រា ១៣) ។

៤៤. គណៈកម្មាធិការជំរុញលើទឹកចិត្តដល់រដ្ឋភាគីឲ្យពិចារណាចុះហត្ថលេខា និងផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

៤៥. គណៈកម្មាធិការជំរុញលើទឹកចិត្តផងដែរដល់រដ្ឋភាគីឲ្យពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ(ILO) លេខ៨១ (១៩៤៧) ស្តីពីអធិការកិច្ចការងារក្នុងវិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម និងអនុសញ្ញាលេខ១០២ (១៩៥២) ស្តីពីបទដ្ឋានអប្បរមានៃការធានារ៉ាប់រងផ្នែកសង្គម (របបសន្តិសុខសង្គម) ។

៤៦ . គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីធ្វើការផ្សព្វផ្សាយសេចក្តីសន្និដ្ឋានចុងក្រោយនេះ ឲ្យបានទូលំទូលាយនៅគ្រប់វិស័យទាំងអស់នៃសង្គម ហើយជូនដំណឹងទៅគណៈកម្មាធិការវិញអំពីគ្រប់វិធានការទាំងអស់ដែលបានចាត់ឡើង ដើម្បីអនុវត្តសេចក្តីសន្និដ្ឋានចុងក្រោយនេះ នៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន ។

៤៧ . គណៈកម្មាធិការផ្តល់ជាអនុសាសន៍ដល់រដ្ឋភាគីឲ្យស្វែងរកការជួយឧបត្ថម្ភពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR Cambodia Country Office) ពាក់ព័ន្ធនឹងការអនុវត្តន៍សេចក្តីសន្និដ្ឋានចុងក្រោយទាំងនេះ ព្រមទាំង ក្នុងការរៀបចំរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន ។ គណៈកម្មាធិការជំរុញលើទឹកចិត្តផងដែរឲ្យរដ្ឋភាគីបន្តធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលនានា និងសមាជិកសង្គមស៊ីវិលផ្សេងៗក្នុងដំណើរការពិភាក្សានៅថ្នាក់ជាតិជាមុនមុននឹងដាក់ស្នើរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួនទៅគណៈកម្មាធិការ ។

៤៨. គណៈកម្មាធិការអញ្ជើញរដ្ឋភាគីឲ្យដាក់ស្នើឯកសារខ្លឹមសាររួមនៃបាយការណ៍ (a common core document) ស្របតាមគោលការណ៍ណែនាំទូទៅស្តីពីការធ្វើរបាយការណ៍ សំរាប់ដាក់ជូនស្ថាប័នឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ (HRI/GEN/2/Rev.5)

៤៩. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីដាក់ស្នើ បញ្ចូលគ្នានូវរបាយការណ៍តាមកាលកំណត់លើកទីប្រាំ និង លើកទីប្រាំមួយរបស់ខ្លួន ស្របតាមគោលការណ៍ណែនាំស្តីពីការធ្វើរបាយការណ៍តាមសន្ធិសញ្ញាជាក់លាក់ របស់គណៈកម្មាធិការ (E/C.12/2008/2) ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២ ។

----- ចប់ -----